**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៩៧/០៣/២០១៤ កបធ.សជណ

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤

**សូមគោរពជូន**

**ឯកឧត្តម ឌិត មុន្ទី ប្រធានតុលាការកំពូល**

**កម្មវត្ថុ :** ករណីពាក្យបណ្ដឹងសុំអន្តរាគមន៍របស់លោកស្រីមេធាវី **សំ នារី** ។

**យោង :** លិខិតលេខ ១៦៩/១៤ តកក.សរវ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤ របស់ឯកឧត្តម ។

តបតាមកម្មវត្ថុ និង យោងខាងលើ យើងខ្ញុំសូមជម្រាបឯកឧត្តមប្រធានតុលាការកំពូល មេត្តាជ្រាបថា ក្នុងកិច្ចប្រជុំពេញអង្គ នាថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៤ ក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យលិខិត លេខ ១៦៩/១៤ តកក.សរវ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៤ របស់ឯកឧត្តមរួចហើយ និងសូមអនុញ្ញាត ជម្រាបជូនឯកឧត្តមមេត្តាជ្រាបដូចតទៅ :

១-មាត្រា ១៣៦ ថ្មី វាក្យខ័ណ្ឌទី១ ជំពូកទី ១២ ថ្មី នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ចែងថា "*ក្រុមប្រឹក្សាធម្មនុញ្ញ មានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ។*"

២-មាត្រា ១៥ ថ្មី ផ្នែកទី២ ជំពូកទី២ នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញចែងថា "*ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និង ច្បាប់ដែលរដ្ឋសភាបានអនុម័ត និង ព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ ក្នុងក្របខ័ណ្ឌនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ។*"

៣-មាត្រា ១៨ ថ្មី នៃច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញចែងថា "*ក្រោយពីច្បាប់ណាមួយត្រូវបានប្រកាសឱ្យប្រើ ព្រះមហាក្សត្រ ប្រធានព្រឹទ្ធសភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន សមាជិករដ្ឋសភាចំនួនមួយភាគដប់ ឬតុលាការ អាចសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យអំពីធម្មនុញ្ញភាពនៃច្បាប់នោះ ។*

*ប្រជារាស្ត្រមានសិទ្ធិប្តឹងអំពីអធម្មនុញ្ញភាពនៃច្បាប់ ឬ សុំឱ្យបកស្រាយច្បាប់ ទៅក្រុមប្រឹក្សាធម្មនុញ្ញបាន តាមរយៈប្រធានរដ្ឋសភា ឬ តំណាងរាស្ត្រ ឬ ប្រធានព្រឹទ្ធសភា ឬ សមាជិកព្រឹទ្ធសភា ដូចមានចែងក្នុងវាក្យខ័ណ្ឌខាងលើ ។ "*

៤-មាត្រា ១៩ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ចែងថា *"បុគ្គលដែលជាប់ពាក់ព័ន្ធក្នុងរឿងក្តីណាមួយ ហើយរឿងក្តីនោះឡើងដល់តុលាការ បុគ្គលនោះអាចលើកអំពីអធម្មនុញ្ញភាពនូវបទប្បញ្ញត្តិណាមួយនៃច្បាប់ ឬ សេចក្តីសម្រេចរបស់ស្ថាប័ននានា ដែលគេអះអាងថា ប៉ះពាល់ដល់សិទ្ធិសេរីភាពជាសារវន្តណាមួយរបស់គេជូនតុលាការបាន ។*

*បើយល់ឃើញថា ការលើកឡើងនេះមានមូលដ្ឋានគ្រប់គ្រាន់ តុលាការត្រូវលើកករណីនេះទៅតុលាការកំពូលក្នុងរយៈពេល ១០ ថ្ងៃយ៉ាងយូរ ។*

*តុលាការកំពូលត្រូវចាត់ការពិនិត្យ និង ប្តឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ១៥ ថ្ងៃ*